# ចលនាពលរដ្ឋដើម្បីប្រជាធិបតេយ្យ

**THE PEOPLE MOVEMENT FOR DEMOCRACY**

*ពលរដ្ឋខ្លាំង ជាតិខ្លាំង*

**STRONG PEOPLE   STRONG NATION**

ច.ព.ធ.
P.M.D.

លេខ: ០០១/២០២១ ច.ព.ធ.

សហរដ្ឋអាមេរិក ថ្ងៃទី១២ ខែតុលា ឆ្នាំ២០២១

## សេចក្តីថ្លែងការណ៍

## ប្រឆាំងវិសោធនកម្មរដ្ឋធម្មនុញ្ញ ដែលដាក់ឈ្មោះថា «សេចក្តីព្រាងច្បាប់ធម្មនុញ្ញ»

***ចលនាពលរដ្ឋដើម្បីប្រជាធិបតេយ្យ*** សូមប្រកាសជំហរ ប្រឆាំងជាចំហនិងដាច់ខាតនឹង «សេចក្តីព្រាងច្បាប់ធម្មនុញ្ញ» ដែលបិទសិទ្ធិជនជាតិពូជឈាមខ្មែរ មានសញ្ជាតិពីរ ឬលើសពីពីរ មិនឱ្យធ្វើជា ***ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា*** និង ***នាយករដ្ឋមន្ត្រី***។

ច្បាប់នេះ កើតក្នុងកាលៈទេសៈនេះ ៖

១. គឺជារឿងឥតប្រយោជន៍ចំពោះប្រជាពលរដ្ឋ និងរំខានប្រជាពលរដ្ឋ ពីព្រោះប្រជាពលរដ្ឋខ្មែរ ត្រូវការជីវភាពប្រសើរ និងសេរីភាពបញ្ចេញមតិ ហើយមិនត្រូវការច្បាប់បិទឱកាសជនជាតិដើមកំណើតខ្មែរបែបនេះទេ។

២. គឺជាការបំពានសិទ្ធិប្រជាពលរដ្ឋខ្មែរ ពីព្រោះ ជាវិសោធនកម្មរដ្ឋធម្មនុញ្ញ ដែលធ្វើឲ្យប្រជាពលរដ្ឋខ្មែរ ទាំងក្នុង និងក្រៅប្រទេស មិនពេញចិត្តច្រើនលើសលប់ ប៉ុន្តែមិនបានធ្វើប្រជាមតិត្រឹមត្រូវ ដើម្បីស្ទួរយោបល់ប្រជាពលរដ្ឋ។

៣. កើតក្នុងស្ថានភាពវិបត្តិនយោបាយធ្ងន់ធ្ងរ នៅពេលរដ្ឋសភា និងរដ្ឋាភិបាលសព្វថ្ងៃ មិនស្របនឹងឆន្ទៈប្រជាពលរដ្ឋម្ចាស់ប្រទេស ដូច្នេះមិនមានយុត្តាធិការធ្វើវិសោធនកម្មច្បាប់ និងធ្វើច្បាប់ថ្មី ជាតំណាងបុព្វហេតុជាតិទេ។

៤. គឺជារឿងឥតបានការចំពោះប្រទេសជាតិ ពីព្រោះជាតិកម្ពុជាបច្ចុប្បន្ន ត្រូវការការបង្រួបបង្រួមផ្សះផ្សាគ្នា ហើយមិនត្រូវការហែកចែកទស្សនៈគំនិតគ្នា ករណីសញ្ជាតិមួយ ឬលើសពីមួយឡើយ។

៥. បំពានលើគោលការណ៍ប្រជាធិបតេយ្យសេរីពហុមតិ ដែលមានចែងក្នុងកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស៍ ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ និងរដ្ឋធម្មនុញ្ញកម្ពុជា ថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ពីព្រោះស្មារតីដើមនៃច្បាប់កំពូលទាំងពីរនេះ បើកឱកាសឲ្យពលរដ្ឋខ្មែរគ្រប់រូប ទោះសញ្ជាតិប៉ុន្មាន មានសិទ្ធិជាម្ចាស់ប្រទេស និងប្រកួតគ្នាដោយសេរីបើកចំហ និងត្រឹមត្រូវ។

៦. ប្រមាថ និងព្រមានដោយចំពោះ ទៅលើ***ព្រះករុណា ព្រះមហាក្សត្រ*** និង ***ព្រះរាជបល្ល័ង្ក*** នៅពេល***ព្រះករុណា ព្រះមហាក្សត្រ*** មានសញ្ជាតិលើសពីមួយ។

***ចលនាពលរដ្ឋដើម្បីប្រជាធិបតេយ្យ*** ទទូចដាច់អហង្ការឲ្យអ្នកមានអំណាចកំពូលនៅកម្ពុជា ត្រូវតែទម្លាក់ចោលនូវដំណើរការ«សេចក្តីព្រាងច្បាប់ធម្មនុញ្ញ»នេះជាបន្ទាន់៕

**ប្រធានប្រតិបត្តិ**

**ទូច វិបុល**

Address: 10000 Shadow Ridge Dr. High Point, NC 27265 | pmd.khmer@gmail.com | (336) 663-3071